**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**
**គ.ជ.ប.ជ**

ឯកសារជំនួយស្មារតី៖ របាយការណ៍ស្តីពី

## កិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ និងក្រសួងពាក់ព័ន្ធ ក្នុងការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ស្របតាមសំណូមពរនៃការវាយតម្លៃ

ការវាយតម្លៃរបស់សហរដ្ឋអាមេរិក ក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៤ បានដាក់កម្ពុជាឲ្យស្ថិតក្នុងចំណាត់ថ្នាក់លេខ២ ក្នុងការឃ្លាំមើល ហើយដែលនឹងត្រូវចាត់ក្នុងចំណាតើថ្នាក់លេខ៣ជាស្វ័យប្រវត្តិក្នុងឆ្នាំ ២០១៥ ។ មូលហេតុចម្បង ដែលបានបង្ហាញដោយក្រសួងការបរទេសសហរដ្ឋអាមេរិក គឺផ្តោតទៅលើ១៦ចំណុច ពាក់ព័ន្ធនឹងក្រសួងស្ថាប័នមួយចំនួន ដែលត្រូវផ្តោតការយកចិត្តទុកដាក់ធ្វើឲ្យសម្រេចលើការងារផ្តន្ទាទោស ការងារអនុវត្តច្បាប់ ការងារជួយជនរងគ្រោះនៅក្រៅប្រទេស ការធ្វើមាតុភូមិនិវត្ត ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម ការផ្តល់សេវាសមស្រប ការថែទាំ ជនរងគ្រោះ ការបង្ការទប់ស្កាត់ករណីរងគ្រោះ ដោយផ្តោតការយកចិត្តទុកដាក់លើក្រុមគោលដៅជាស្ត្រី ជាកុមារ និងជាបុរសជាដើម ។ ក្នុងនោះ ក្រសួងដែលពាក់ព័ន្ធសំខាន់ មាន៖ ក្រសួងយុត្តិធម៌ តុលាការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ និងសមត្ថកិច្ចពាក់ព័ន្ធ និងក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ក្នុងគណៈកម្មាធិការជាតិ គ.ជ.ប.ជ ។

ក្រសួងស្ថាប័ន ទាំងឡាយ បានបន្តជម្រុញកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនយ៉ាងសកម្ម តែមិនសូវផ្តល់របាយការណ៍ ឲ្យបានជាក់លាក់ ទៀងទាត់ និងទាន់ពេលវេលា ដែលជាហេតុនាំឲ្យ បាត់ពត៌មានជាច្រើន មិនបានផ្តល់ឲ្យអ្នកវាយតម្លៃ ធ្វើឲ្យមានតែរបាយការណ៍ពីអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើកិច្ចការក្នុងរង្វង់គោលដៅតូចៗ និងមើលឃើញតែចំណុចខ្វះខាត និងមិនឃើញពីការឆ្លើយតប ឬដំណោះស្រាយជាគោលនយោបាយ ។

ដោយឡែក គណៈកម្មាធិការជាតិ គ.ជ.ប.ជ បានចាត់ទុកឆ្នាំ២០១៤ ជាឆ្នាំកសាងនូវមូលដ្ឋានគ្រឹះ និងយុទ្ធសាស្ត្រសម្រាប់និរន្តរភាពការងារយូរអង្វែង ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាបទល្មើសឆ្លងដែន និងមានអង្គការចាត់តាំង និង ជាបទល្មើសដែលពាក់ព័ន្ធនឹងការអូសទាញមនុស្សពេញកម្លាំងពលកម្មសម្រាប់ការកសាង និងអភិវឌ្ឍន៍ជាតិ គ្រប់វិស័យ ឲ្យធ្លាក់ក្នុងភាពរងគ្រោះលើផ្លូវកាយ ផ្លូវចិត្ត ប្រាជ្ញាស្មារតី និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។ ផលប៉ះពាល់នៃអំពើជួញដូរមនុស្ស នឹងជះឥទ្ធិពលយូរអង្វែង ទៅលើគ្រួសារពលករ សហគមន៍ និងសង្គមជាតិ ។ វិបត្តិដែលបង្កដោយអំពើជួញដូរមនុស្ស គឺភាពរងគ្រោះ និងអំពើកេងប្រវ័ញ្ចគ្រប់រូបភាពទៅលើយុវវ័យ មនុស្សពេញកម្លាំងការងារ ស្ត្រី និងកុមារ ។ សង្គមជាតិ ប្រឈមនឹងការគ្រប់គ្រងកម្លាំងពលកម្ម ដែលកំពុងតែហូរចេញចូលយ៉ាងអនាធិបតេយ្យ ដែលជាការហូរចេញនូវធនធានមនុស្សដែលមានកម្លាំងមាំមួន និងហូរចូលមកវិញនូវជនដែលបាត់បង់កាយសម្បទា ប្រាជ្ញាស្មារតីចុះខ្សោយ ឥរិយាបទមិនប្រក្រតី គ្រួសារបែកបាក់ មិនមានការថែទាំកូនក្នុងបន្ទុក ឬមនុស្សចាស់ជរា ជាដើម ហើយបាន និងកំពុងក្លាយជាបន្ទុកយ៉ាងធ្ងន់ធ្ងររបស់រាជរដ្ឋាភិបាល។ ក្រសួងស្ថាប័នទាំងឡាយ មិនអាចធ្វើសកម្មភាពដោយមិនមានគោលដៅជាយុទ្ធសាស្ត្ររួម មិនមានការប្រមូលផ្តុំ និងកិច្ចសហការ

បានឡើយ ។ ហេតុនេះហើយ ទើបគណៈកម្មាធិការជាតិ គ.ជ.ប.ជ បានដើរតួយ៉ាងសំខាន់ ក្នុងការសម្របសម្រួល និងប្រមូលផ្តុំគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់គ្រប់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីធ្វើឲ្យរាជរដ្ឋាភិបាល អាចសម្រេចទិសដៅ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សបាន ។

ដើម្បីបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបទៅនឹងចំណុចខ្វះខាតខាងលើ គណៈកម្មាធិការជាតិ គ.ជ.ប.ជ បានប្រជុំពិភាក្សា និងប្រមូលរបាយការណ៍ពីក្រសួងពាក់ព័ន្ធ មានជាអាទិ៍ដូចខាងក្រោម៖

**១. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖**

I-វិធានការទប់ស្កាត់ និងជួយជនរងគ្រោះ

១-ផ្សព្វផ្សាយដល់ប្រជាជន និងពលករ កុំឲ្យធ្វើចំណាកស្រុកដោយប្រថុយប្រថាន

២-លេខទូរស័ព្ទ Hot lines នៅស្ថានទូត និងនាយកដ្ឋានកុងស៊ុលនៃក្រសួងការបរទេស ដើម្បីទទួលពាក្យបណ្តឹង និងជួយជនរងគ្រោះ។

II-ការជួយពលរដ្ឋខ្មែររងគ្រោះនៅបរទេស (ករណីគ្មានស្ថានទូតកម្ពុជាតាំងនៅ)

១-ស្ថានទូតកម្ពុជាដែលនៅជិតបំផុតជួយដោះស្រាយពេលទទួលបានដំណឹងពីការជួញដូរមនុស្ស

-ស្ថានទូតបានទាក់ទងអាជ្ញាធរនៃប្រទេសដែលជនរងគ្រោះស្នាក់នៅ ដើម្បីអន្តរាគមន៍ជួយនិងផ្តល់ កន្លែងសុវត្ថិភាពដល់ជនរងគ្រោះ និងតាមចាប់ជនឧក្រិដ្ឋនៃអំពើជួញដូរមនុស្ស។

-សហការជាមួយអង្គការ IOM ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ និងធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។

<u>ឆ្នាំ ២០១១</u>៖ ស្ថានទូតទូតកម្ពុជានៅម៉ាឡេស៊ី សហការជាមួយអង្គការ IOM និងអាជ្ញាធរនៃប្រទេសម៉ូរីស បានជួយពលរដ្ឋខ្មែរ ២៧ នាក់ វិលត្រឡប់មកកម្ពុជាវិញ។

<u>ឆ្នាំ ២០១២</u>៖ ស្ថានទូតទូតកម្ពុជានៅឥណ្ឌូនេស៊ី សហការជាមួយអង្គការ IOM និងអាជ្ញាធរនៃប្រទេសៈ

-សេណេហ្គាល: ១១ នាក់

-ហ្វីជី: ១១ នាក់

-អាហ្វ្រិកខាងត្បូង: ០៤ នាក់

-ម៉ៀកូណេស៊ីៈ ០៧ នាក់

<u>ឆ្នាំ ២០១៣</u>៖ ស្ថានទូតទូតកម្ពុជានៅម៉ាឡេស៊ី សហការជាមួយអង្គការ IOM និងអាជ្ញាធរនៃប្រទេសម៉ូរីស បានជួយពលរដ្ឋខ្មែរ ២៤ នាក់ វិលត្រឡប់មកកម្ពុជាវិញ។

<u>ឆ្នាំ ២០១៤</u>៖ ស្ថានទូតកម្ពុជានៅគូវ៉ែត សហការជាមួយអង្គការ IOM ស្ថានទូតថៃ នៅអារ៉ាប់ប៊ី-សាអ៊ូឌីត និងអាជ្ញាធរនៃប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីតៈ

-បានជួយពលរដ្ឋខ្មែរ ០៧ នាក់ បានវិលត្រឡប់មកកម្ពុជាវិញ។

-ពលរដ្ឋខ្មែរ ០២ នាក់ ទៀតកំពុងដោះស្រាយ ដើម្បីបានវិលត្រឡប់មកកម្ពុជាវិញ។

III-ស្ថានទូត-ស្ថានកុងស៊ុលកម្ពុជានៅក្រៅប្រទេស សហការជាមួយអង្គការ IOM និងអាជ្ញាធរ

១-សាធារណរដ្ឋប្រជាមានិតចិនៈ

-ឆ្នាំ ២០១៣ ៖ ៣៤ នាក់

-ឆ្នាំ ២០១៤ ៖ ១៣៥ នាក់

២-ឥណ្ឌូនេស៊ីៈ

-ឆ្នាំ ២០១៣ ៖ ៣៦ នាក់

-ឆ្នាំ ២០១៤ ៖ ២៣ នាក់

៣-ម៉ាឡេស៊ីៈ

-ឆ្នាំ ២០១៣ ៖ ៤៥ នាក់

-ឆ្នាំ ២០១៤ ៖ ០៧ នាក់

IV-មន្ត្រីការទូតទទួលបន្ទុកការងារពលករប្រចាំស្ថានទូតកម្ពុជានៅបរទេសៈ

- នៅសាធារណរដ្ឋ កូរ៉េ មានទីប្រឹក្សាការងារ (មន្ត្រីក្រសួងការងារ)។
- នៅម៉ាឡេស៊ី មន្ត្រី ០២ នាក់ទទួលបន្ទុកការងារពលករ និងតំណាងសមាគមនាំពលករទៅធ្វើការនៅក្រៅប្រទេស (អាក្រា) ០១ នាក់។
- នៅថៃ មានមន្ត្រី ០១ នាក់ទទួលបន្ទុកការងារពលករ និងតំណាងសមាគមជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស(អាក្រា) ០១ នាក់។
- មន្ត្រីការទូតទទួលបន្ទុកការងារពលករ ត្រូវបានណែនាំពីការងារជួយជនរងគ្រោះនៃការជួញដូរមនុស្ស មុនពេលទៅបំពេញបេសកកម្មការទូតនៅក្រៅប្រទេស។
- មន្ត្រីទទួលបន្ទុកពលករតែងតែទាក់ទងមកក្រសួងជាប្រចាំដើម្បីទទួលបានអនុសាសន៍ណែនាំពីក្រសួង នៅពេលមានពលករត្រូវគេជួញដូរមកស្នើឲ្យជួយសង្គ្រោះ ។

## ២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១. ការរៀបចំ និងផ្សព្វផ្សាយគោលនយោបាយ និងគោលការណ៍

- បាន និងកំពុងពិនិត្យ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់កម្ពុជា ឆ្នាំ២០១០
- បានធ្វើ ឯកសារណែនាំស្តីពីការត្រៀមចេញដំណើរ សម្រាប់ឲ្យទីភ្នាក់ងារជ្រើសរើសឯកជននានាអនុវត្តដោយឯកភាព នៅតាមមណ្ឌលណែនាំតម្រង់ទិសនីមួយៗ និងកំពុងបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់បន្តធ្វើការងារនេះ ។
- កំពុងធ្វើប្រកាសបន្ថែម (ទី៩) សម្រាប់ពង្រឹងការអនុវត្តន៍អនុក្រឹត្យលេខ ១៩០ អនក្រ បក ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១១ ស្តីពី ការប្រើប្រាស់ប្រាក់កក់ធានា របស់ទីភ្នាក់ងារជ្រើសរើសឯកជន ។
- កំពុងធ្វើ សម្រាប់ការធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន(*PRAs*) និងមណ្ឌលកែប្រែតម្រង់ទិស សម្រាប់ការពង្រឹងប្រសិទ្ធភាពនៃអធិការកិច្ច
- លើកកម្ពស់ការយល់ដឹង តាមរយៈសិក្ខាសាលា គ្រប់សមាសភាពពាក់ព័ន្ធ អំពីដំណើរការនៃការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង លំហូរពលករខ្មែរដែលទៅធ្វើការនៅបរទេស ជាពិសេសក្នុងតំណាក់កាលថ្មី នៃការគ្រប់គ្រង ឆ្លើយតបទៅនឹងកំណើន និងការប្រែប្រួលនៃលំហូរពលកម្មខ្មែរឆ្លងដែនទៅបរទេស ។
- ការដាក់ឲ្យអនុវត្តកិច្ចសន្យា ការងារគម្រូ ជាទូទៅ សម្រាប់ការចុះកិច្ចសន្យាទៅធ្វើការនៅបរទេស ដោយទីភ្នាក់ងារជ្រើសរើសឯកជន ដោយមានការគាំទ្របច្ចេកទេសពីអង្គការអន្តរជាតិ អង្គការវិជ្ជាជីវៈ របស់និយោជក កម្មករ និងសង្គមស៊ីវិល ។

២. ការបង្កើតឲ្យមានយន្តការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ខ្មែរ (ជាពិសេស ទៅប្រទេសថៃ)

- ការបង្កើតច្រកចេញចូលតែមួយ សម្រាប់សម្របសម្រួល ធ្វើបែបបទ ទទួលចុះឈ្មោះ និងទទួលធ្វើលិខិតឆ្លងដែនជូនពលករ ទៅតាមខេត្តនីមួយៗ និងបង្កើតច្រកចំនួន០៤ តាមបណ្តោយព្រំដែនកម្ពុជាថៃ ។ (ប្រកាសអន្តរក្រសួង លេខ២៥៧៤ ប្រក ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើលិខិតឆ្លងដែនធម្មតា ជូនពលករ ពលការិនីខ្មែរ ទៅធ្វើការស្របច្បាប់នៅបរទេស) ។ នៅតាមខេត្តនីមួយៗ មន្ទីរការងារ និងស្នងការនគរបាល ខេត្ត បានសហការគ្នារៀបចំបង្កើតច្រកចេញចូលតែមួយនេះ និងកំពុងបន្តអនុវត្ត ។
- ការបង្កើតក្រុមការងារអន្តរក្រសួងចល័ត ចំនួន ០៦ ដោះស្រាយផ្តល់ភាពស្របច្បាប់ ជូនពលករខ្មែរនៅប្រទេសថៃ ដោយចេញសេចក្តីសម្រេចលេខ ០២៥ កប សសរ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងចល័ត និងក្រុមបោះពុម្ពលិខិតឆ្លងដែន ដើម្បីផ្តល់ភាពស្របច្បាប់ដល់ពលរដ្ឋកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅព្រះរាជាណាចក្រថៃឡង់ ។ ក្រុមការងារអន្តរក្រសួងចល័តចំនួន ០៥ និងក្រុមបោះពុម្ពលិខិតឆ្លងដែន ចំនួន ០១ត្រូវបានបង្កើត និងកំពុងអនុវត្តភារកិច្ចរបស់ខ្លួននៅលើទឹកដីថៃ ។

៣. អំពីការបង្កើតប្រព័ន្ធជួយពលករខ្មែរនៅបរទេស និងជនរងគ្រោះ

- ចាត់បញ្ជូនមន្ត្រីជាទីប្រឹក្សាអមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជានៅសាធារណរដ្ឋកូរ៉េ ទទួលបន្ទុកជាអនុព័ន្ធការងារ ។
- ចាត់ឲ្យមានអ្នកតំណាងទីភ្នាក់ងារឯកជនកម្ពុជា ប្រចាំនៅប្រទេសទទួលពលករ សម្រាប់ឃ្លាំមើល និងជួយសម្រួល ដោះស្រាយបញ្ហាពលករ ។
- បង្កើតមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ ដោយមានផ្នែកផ្តល់ព័ត៌មានសំខាន់ៗ និងទទួលដោះស្រាយបណ្តឹង តវ៉ា របស់ពលករ នៅក្នុងខេត្តចំនួន ០៥ និងបណ្តឹងមួយចំនួនទៀត ត្រូវបានដាក់ទៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ។

៤. ការដាក់ទោសទណ្ឌ ក្រុមហ៊ុនដែលប្រព្រឹត្តខុស

- ដាក់ចេញ និងជម្រុញអនុវត្តខ្លឹមសារចំនួនប្រកាស០៨ ជានីតិវិធីសម្រាប់ការអនុវត្តអនុក្រឹត្យលេខ ១៩០ ឲ្យមានប្រសិទ្ធភាព ។
- បច្ចុប្បន្ន ក្រសួង បានធ្វើអធិការកិច្ច និងណែនាំតម្រង់ទិស និងកែលំអចំណុចសេសសល់ ដែលក្រុមហ៊ុនមិនទាន់ធ្វើបានល្អប្រសើរ ។
- ដោះស្រាយការតវ៉ាជាបុគ្គល និងជាសមូហភាព ដោយសម្របសម្រួល (ផ្សះផ្សា)ឲ្យបានត្រូវគ្នា (សះជា)វិញជាបន្តបន្ទាប់ និងកាត់បន្ថយបានការបន្តនីតិវិធីទៅតុលាការ ។

៥. អនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសទទួល

- បានរៀបចំសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា និងម៉ាឡេស៊ី ស្តីពីជ្រើសរើស និងប្រើប្រាស់កម្លាំងពលកម្មកម្ពុជា ដែលមានការចូលរួម និងគាំទ្របច្ចេកទេសពីអង្គការអន្តរជាតិ អង្គការវិជ្ជាជីវៈ របស់និយោជក កម្មករ និងសង្គមស៊ីវិល ព្រមទាំងបានរៀបចំឯកសារកិច្ចសន្យាគំរូសម្រាប់ការអនុវត្តឲ្យឯកភាពគ្នា ។
- បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយភាគីថៃស្តីពីកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ការជួញដូរមនុស្សឆ្លងដែន ក្នុងខែតុលា ឆ្នាំ២០១៤ ។
- ចរចា ជាមួយភាគីថៃ ដើម្បីពិនិត្យកែសម្រួលប្រការ៩ នៃអនុស្សរណៈយោគយល់គ្នា ឆ្នាំ២០០៣ ស្តីពីការបញ្ជូនពលករខ្មែរ ទៅធ្វើការដោយស្របច្បាប់ក្នុងប្រទេសថៃ ដើម្បីការពារសិទ្ធិពលករ ។

## ៣. ក្រសួងអប់រំ យុវជន និងកីឡា

ឆ្លើយតបគោលបំណងខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់កម្រិតជំនាញពាក់ព័ន្ធ និងបានធ្វើរបាយការណ៍សង្ខេបដូចខាងក្រោម៖

១. ទិដ្ឋភាពរួម

បញ្ហាអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រ និងសកម្មភាពសម្រាប់អនុវត្តដើម្បីបង្ការ ទប់ស្កាត់នៅក្នុងកម្មវិធីសិក្សា និងការបណ្តុះបណ្តាលនានាទាំងក្នុងនិងក្រៅប្រព័ន្ធនៃវិស័យអប់រំចាប់តាំងពីឆ្នាំ ២០០៧ រហូតមកដល់បច្ចុប្បន្ននេះ។

២. ខ្លឹមសារអនុវត្តក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា

ដើម្បីធានាបានប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ការអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមាររហូតមកដល់បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាបានចាត់ចែងដូចខាងក្រោម៖

- បានបញ្ចូលខ្លឹមសារ និងគោលដៅទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ទៅក្នុងគោលនយោបាយអប់រំជាតិ គោលនយោបាយជាតិស្តីពីគាំពារនិងអភិវឌ្ឍន៍ កុមារតូច គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា គោលនយោបាយស្តីពីការងារអប់រំក្រៅប្រព័ន្ធ គោលនយោបាយស្តីពីសាលាកុមារមេត្រី និងគោលនយោបាយជាតិនានា។

- បានរៀបចំឱ្យមានរចនាសម្ព័ន្ធ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ លើស្ត្រីនិងកុមារចាប់តាំងពីថ្នាក់ក្រសួង មន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងនៅគ្រប់គ្រឹះស្ថានសិក្សាទូទាំងប្រទេស
- រៀបចំឱ្យមានរចនាសម្ព័ន្ធតាមរយៈការកសាងនិងពង្រឹងគុណភាពក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន គណៈកម្មការមាតាបិតាសិស្សនៅតាមគ្រឹះស្ថានសិក្សាចំនួន ៩០៩៦។
- បានបង្កើតប្រព័ន្ធហតឡាញ(Hotline) ទំនាក់ទំនងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងគ្រឹះស្ថានសិក្សាបង្គោល។
- បានផ្សព្វផ្សាយពង្រឹងការយល់ដឹងអំពីក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងល្បិចកលជនខិលខូចជូនដល់បុគ្គលិកអប់រំ និងក្រុមការងារចាប់តាំងពីឆ្នាំ២០០៧មក។ ជាក់ស្តែង ក្នុងឆ្នាំ២០១៣-២០១៤ ក្រសួងបានផ្សព្វផ្សាយនិងពង្រឹងការយល់ដឹងដល់បុគ្គលិកអប់រំនៅខេត្តកំពត ព្រះសីហនុ កំពង់ស្ពឺ បន្ទាយមានជ័យ ប៉ៃលិន សៀមរាប កំពង់ធំ កំពង់ចាម ព្រៃវែង កណ្តាល ស្វាយរៀង និងកំពង់ឆ្នាំងដែលមានបុគ្គលិកអប់រំចូលរួមចំនួន ៥៩៤នាក់ ក្នុងនោះស្ត្រីមាន១៤៣នាក់ ស្មើ២០.០៧%។
- បានដាក់បញ្ចូលការអប់រំទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់ភេទទៅក្នុងកម្មវិធីសិក្សាសង្គមវិជ្ជា មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជានៅថ្នាក់ទី២ ទី៣ ទី៤ និងថ្នាក់ទី១០។

## ៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ឆ្លើយនឹងចំណុច៖

ឆ. ធ្វើបញ្ជាប់ និងអនុវត្តពិធីសារ នីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យបានទូទាំងប្រទេស ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ៖

- សហការជាមួយអង្គការវិនរ៉ក់អន្តរជាតិ(Winrock International) UN-ACT កសាងគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានកិច្ចប្រជុំចំនួន ៤ លើក ក្នុងឆ្នាំ២០១១និង២០១២ គាំទ្រដោយអង្គការមូលនិធិអាស៊ី និង UNODC និងបន្តប្រជុំថ្នាក់នយោបាយ៣លើកនៅឆ្នាំ២០១៣ និង កិច្ចប្រជុំបច្ចេកទេស ៨លើក នៅឆ្នាំ២០១៣ និង២០១៤ សិក្ខាសាលាថ្នាក់ជាតិ ០១លើក និងវគ្គបណ្តុះបណ្តាល នៅខេត្តសៀមរាប ០១លើក ។
- ចុះអនុវត្តសាកល្បង (តេស្ត)នៅរាជធានី និងខេត្តចំនួន ០៥ និងកែសម្រួល និងដាក់ជូនអគ្គលេខាធិការ ដ្ឋានគណៈកម្មាធិការជាតិ ពិនិត្យសម្រេច ។

ញ. ការបង្កើនការបញ្ជូន ជនរងគ្រោះទៅអង្គការមិនមែនរដ្ឋាភិបាល ដើម្បីទទួលសេវានានា

- សកម្មភាពផ្សព្វផ្សាយ និងបណ្តុះបណ្តាល
- បើកវគ្គបណ្តុះបណ្តាល ០៤វគ្គ ស្តីពីគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស
- ចូលរួមផ្សព្វផ្សាយគោលនយោបាយ និងបទដ្ឋានអប្បបរមា ដល់អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣៧ សិក្ខាកាមសរុប ១១៩នាក់ ពាក់ព័ន្ធនឹងការងាររបស់មណ្ឌលទទួលថែទាំជនរងគ្រោះ

ខ. សកម្មភាពជួយជនរងគ្រោះ

- បានធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះវៀតណាមចំនួន ២១នាក់ទៅប្រទេសវៀតណាមវិញ
- ទំនាក់ទំនងជាមួយស្ថានទូតវៀតណាមស្នើសុំប័ណ្ណឆ្លងដែនឲ្យជនរងគ្រោះជាជនជាតិវៀតណាម ស្នាក់នៅក្នុងមណ្ឌលរបស់អង្គការ ហាហ្គាចមនួន ០៦ច្បាប់ និងបានធ្វើមាតុភូមិនិវត្តន៍ ពីរលើក
- ចុះតាមដានស្ត្រី និងកុមាររងគ្រោះ ដោយអំពើជួញដូរមនុស្ស ០៣នាក់ ដែលបានធ្វើមាតុភូមិនិវត្តន៍ឆ្នាំ ២០១៣ ២០១៤ ទៅខេត្ត សុកចាង និងខេត្តអានយ៉ាង ប្រទេសវៀតណាម
- បានរៀបចំឯកសារស្នើសុំអនុញ្ញាតឲ្យជនរងគ្រោះវៀតណាមមួយរូប ដែលស្នាក់ក្នុងមណ្ឌល បានទៅសួរសុខទុក្ខក្រុមគ្រួសារ នៅខេត្តដុងថាប ប្រទេសវៀតណាម

- ពិភាក្សាជាមួយអង្គការ ទេសន្តរប្រវេសន៍អន្តរជាតិ(IOM) និងផ្តល់សេវាជួយជនរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្ម ១២នាក់ (ស្រី ០៥នាក់) មកពីប្រទេសម៉ាឡេស៊ី គាំទ្រដោយ IOM និងធ្វើសមាហរណកម្មទៅស្រុកកំណើត
- មន្ទីរសង្គមកិច្ចក្នុងរាជធានីខេត្តចំនួន ០៧ គឺ រាជធានីភ្នំពេញ ខេត្តពោធិសាត់ កំពត ក្រចេះ សៀមរាប ស្វាយរៀង និងខេត្តបន្ទាយមានជ័យ បានសហការជាមួយដៃគូ ជួយជនរងគ្រោះដោយការជួញដូរមនុស្ស ចំនួន ៣២៦ករណី (ស្រ្តី២៥៧នាក់) និងបានធ្វើសមាហរណកម្មទៅគ្រួសារក្នុងសហគមន៍វិញចំនួន ១៤៨ករណី ឆ្លើយតបទៅនឹងសំណូមពរជួយករណី ១៥ករណី បញ្ជូនទៅរកសេវាផ្សេងៗជាមួយអង្គការដៃគូ ១៣៤ករណី បានបិទករណីចំនួន ០២ និងកំពុងតាមដានបន្ត ២៧ករណី ។
- ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការ IOM និងអង្គការពាក់ព័ន្ធទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន១៤៦នាក់ (ស្រី ១៨នាក់) មកពីប្រទេសឥណ្ឌូនេស៊ី ០៣នាក់ ម៉ាឡេស៊ី ៣៣នាក់ ថៃ១០៤នាក់ និងចិន ០៦នាក់ ។ ជនរងគ្រោះទាំងនោះ បានធ្វើសមាហរណកម្មទៅស្រុកកំណើតវិញ ក្នុងរាជធានី និងខេត្ត ចំនួន ១៦ ។

គ. ការកសាងឯកសារ គោលនយោបាយ និងបទដ្ឋានគតិយុត្តិ

- បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់ក្នុងមណ្ឌល
- ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

  ក្នុងនោះ បានធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឲ្យប្រើប្រាស់សៀវភៅ "ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់ក្នុងមណ្ឌល " ដល់សិក្ខាកាមមកពីមន្ទីរសង្គមកិច្ច ស្ថាប័ន អង្គការជាតិ អន្តរជាតិ ចំនួន ១៣៧នាក់ (ស្រី៤៣នាក់) ។

- សហការជាមួយក្រសួងស្ថាប័ន និងអង្គការដៃគូ ធ្វើសេចក្តីព្រាងឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលនឹងត្រូវបញ្ចប់ក្នុងឆ្នាំ២០១៥ ដោយសហការជាមួយអង្គការ វីនរ៉ក់អន្តរជាតិ ។

ឃ. កែលំអកិច្ចសហប្រតិបត្តិការ រវាងអន្តរទីភ្នាក់ងារ និងសម្របសម្រួលជាមួយមន្ត្រីនគរបាល តុលាការ និងមន្ត្រីពាក់ព័ន្ធ លើករណីជួញដូរមនុស្ស និងដំណើរការ នៃការបញ្ជូនជនរងគ្រោះ

- ក្រសួងកំពុងបន្តសហការក្នុងក្រុមការងារជួយជនរងគ្រោះ និងមានអង្គការមួយចំនួនចូលរួម ដូចជា អង្គការ UN-ACT, Winrock International, World Vision Cambodia, KT, BT, CWCC, Chabdai nig CMC ដែលមានកិច្ចព្រមព្រៀងជាមួយក្រសួង លើសកម្មភាព កសាងឯកសារគតិយុត្តិ ក្នុងបរិបទការពារជនរងគ្រោះ ការបញ្ជូនទៅរកសេវាជួយជនរងគ្រោះ ការតាមដាន និងសមាហរណកម្មជនរងគ្រោះ ។

## ៥. ក្រសួងយុត្តិធម៌៖

ក. ក្រសួងយុត្តិធម៌ យកចិត្តទុកដាក់ លើការឆ្លើយតបរបស់តុលាការទៅនឹងករណីជួញដូរមនុស្ស ។ កន្លងមកនេះ ក្រសួងយុត្តិធម៌ បានចេញលិខិតណែនាំដល់ស្ថាប័នអយ្យការ និងតុលាការចំនួនពីរលើក ។

ខ. បានពិភាក្សាជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីលើកសំណើសុំធ្វើវិសោធនកម្មច្បាប់ ដែលអនុញ្ញាតឲ្យនគរបាលអាចធ្វើការស៊ើបអង្កេតសម្ងាត់ ។

គ. មន្ត្រីរដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនជ្រើសរើសពលករ បើអនុវត្ត ឬធ្វើសកម្មភាពខុសនឹងច្បាប់ព្រហ្មទណ្ឌ នឹងត្រូវទទួលទោស ដូចបុគ្គលដទៃទៀតដែរ ។ កិច្ចការសំខាន់ គឺការស៊ើបអង្កេត មិនមែនផ្អែកលើ ការអះអាងនោះទេ ។

## ៦. នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន

១. ការបង្កើនកិច្ចខិតខំនានា ដើម្បីស៊ើបអង្កេត និង ផ្តន្ទាទោសឲ្យបានពេញទំហឹងនូវរាល់បទល្មើស ព្រមទាំងធ្វើការកាត់ទោស និង ដាក់ទោសទណ្ឌលើជនជួញដូរផ្លូវភេទ និង ជួញដូរពលកម្ម។

ទិន្នន័យបង្ក្រាបរួមក្នុងរយៈពេល ០៩ខែឆ្នាំ២០១៤ មានការកើនឡើង បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៣ ក្នុងនោះរួមមាន ៧៧/៧៣ករណី សង្គ្រោះជនរងគ្រោះ៣៨៤នាក់ ក្នុងនោះអំពើជួញដូរមនុស្ស ៣៦ករណី សង្គ្រោះជនរងគ្រោះ២២២នាក់ និងអាជីវកម្មផ្លូវភេទ៤១ករណី សង្គ្រោះជនរងគ្រោះ១២២នាក់។

២.ដាក់ចេញលិខិតបទដ្ឋាន(ប្រកាស) ដើម្បីប្រតិបត្តិ ឬ សេចក្តីណែនាំជាផ្លូវការផ្សេងៗ ដើម្បីផ្តល់អំណាចឲ្យមានការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតសម្ងាត់ ក្នុងការអនុវត្តច្បាប់ប្រឆាំងនឹងអំពើជួញដូរមនុស្ស។

កន្លងមកមានការពិភាក្សា និង សិក្ខាសាលាជាបន្តបន្ទាប់ អំពីករណីនេះ។ ក្នុងនោះក្រសួងយុត្តិធម៌ក៏បាន ធ្វើការសិក្សាឡើងវិញអំពីច្បាប់កម្ពុជា ដែលពុំបានចែងអំពីករណីនេះ។ ដើម្បីជម្រុញឲ្យមានការធ្វើវិសោធនកម្មច្បាប់ បន្ថែមជំពូកថ្មី ស្តីពីការស៊ើបអង្កេតសម្ងាត់ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន ដែលជាសមត្ថកិច្ចជំនាញបានធ្វើការសិក្សាឡើងវិញ និង ប្រមូលផ្តុំនូវទឡ្ហីករណ៍ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និង ក្រសួងមហាផ្ទៃ អំពីតម្រូវការនៃការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតសម្ងាត់នេះ។ អគ្គស្នងការដ្ឋាននគរបាលជាតិ កំពុងធ្វើការសិក្សា និង ជម្រុញលើការងារនេះ។

៣.កិច្ចប្រឹងប្រែងដើម្បីដាក់វិធានការចំពោះមន្ត្រីឃុបឃិតក្នុងអំពើជួញដូរមនុស្ស។

អគ្គស្នងការដ្ឋាននគរបាលជាតិ បានជម្រុញការត្រួតពិនិត្យ និង គ្រប់គ្រងមន្ត្រីក្រោមឱវាទជាទៀងទាត់។

ដោយឡែកមន្ត្រីដែលពាក់ព័ន្ធបទល្មើស តែងត្រូវបានចាត់វិធានការផ្លូវច្បាប់ និង កសាងសំណុំរឿងបញ្ជូនទៅតុលាការ។

៤.ផ្សព្វផ្សាយឲ្យមន្ត្រីអនុវត្តច្បាប់ និង អ្នកធ្វើគោលនយោបាយ បានជ្រួតជ្រាបពីភាពរីករាលដាលនៃអំពើ ជួញដូរបុរសពេញវ័យ ជាពិសេសក្នុងឧស្សាហកម្មនេសាទ និងបង្កើតសេវាកម្មបន្ថែមសម្រាប់ជនរងគ្រោះជាបុរស

ក្រោយការបង្ក្រាបក្រុមហ៊ុន GIANT OCEAN INTERNATIONAL FISHERIES CO.,LTD ពាក្យបណ្តឹង ពាក់ព័ន្ធនឹងពលករលើទូកនេសាទមានការថយចុះ។

៥.អនុវត្តនូវការដាក់ទោសព្រហ្មទណ្ឌ ចំពោះបណ្តាក្រុមហ៊ុនដែលជ្រើសរើសពលករទាំងឡាយដែល ពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់ ដែលជាកត្តានាំឲ្យកើតមានអំពើជួញដូរ។

ក្រោយការផ្អាកការជ្រើសរើស បណ្តុះបណ្តាល និង បញ្ជូនពលការិនីទៅបម្រើការងារមេផ្ទះនៅប្រទេសម៉ាឡេស៊ី និង ការសម្របសម្រួលបែបបទផ្លូវច្បាប់សម្រាប់ពលករខុសច្បាប់នៅប្រទេសថៃ បានធ្វើឲ្យក្រុមហ៊ុនជ្រើសរើសពលករមួយចំនួនធំ មិនអាចដំណើរការអាជីវកម្មបាន ឬបានកាត់បន្ថយនូវអាជីវកម្មរបស់ខ្លួន។

## ៧. គណៈកម្មាធិការជាតិ គ.ជ.ប.ជ

ពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិ គ.ជ.ប.ជ សកម្មភាពជាអាទិភាព ក្នុងឆ្នាំ២០១៤ នេះ មានដូចខាងក្រោម៖

- បានសហការជាមួយ អង្គការវិនរ៉ក់អន្តរជាតិ និងអង្គការដៃគូដទៃទៀត ធ្វើការវាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការជាតិ ឆ្នាំ២០១១-២០១៣

- កសាងផែនការសកម្មភាពជាតិ និងយុទ្ធសាស្ត្រជាតិ រយៈពេលប្រាំឆ្នាំ បន្ត ២០១៤-២០១៨ ដែលនឹងត្រូវបោះពុម្ព ចែកផ្សាយ នៅចុងឆ្នាំ ២០១៤នេះ ។
- សម្របសម្រួលជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ កែសម្រួលយន្តការជាតិ ដោយបង្កើតជាថ្មី នូវគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានវិសាលភាពទូលំទូលាយជាងមុន មានការរួមបញ្ចូលគ្រប់យន្តការដែលមានស្រាប់ ឲ្យនៅតែមួយ មានអគ្គលេខាធិការដ្ឋានសម្រាប់ជាសេនាធិការ មានក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន ទទួលបន្ទុកដឹកនាំដោយក្រសួងជំនាញលើការងារជាយុទ្ធសាស្ត្រ មានការងារបង្ការទប់ស្កាត់ ការងារជួយជនរងគ្រោះ ការងារអនុវត្តច្បាប់ (បង្ក្រាប និងសង្គ្រោះ) ការងារយុត្តិធម៌ (ការផ្តន្ទាទោស) ការងារពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការងារទេសន្តរប្រវេសន៍ និងបានរៀបចំរចនាសម្ព័ន្ធសម្រាប់គណៈកម្មាធិការ និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិ ដែលគ្របដណ្តប់ដល់បណ្តាញមន្ត្រីទទួលខុសត្រូវ នៅថ្នាក់ឃុំសង្កាត់ និងតួនាទីភារកិច្ចរបស់គ្រប់រចនាសម្ព័ន្ធនៃយន្តការគ្រប់ថ្នាក់ ។
- យន្តការគ្រប់ថ្នាក់ បានត្រូវកំណត់ដោយ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស តាមឋានានុក្រម និងកំពុងតែងតាំងមន្ត្រីបម្រើការ ឲ្យបានគ្រប់គ្រាន់ ហើយនឹងបន្តបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ច និងចុះធ្វើសកម្មភាពក្នុងពេលដ៏ខ្លីខាងមុខនេះ ។
- ទន្ទឹមនឹងនេះ ការប្រមូល ចងក្រងរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ បានដំណើរការជាប្រក្រតី និងបានជួបពិភាក្សាការងារ ផែនការ និងផ្លាស់ប្តូរយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូជាតិ និងអន្តរជាតិ ជាប្រចាំ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៤

អនុប្រធានអចិន្ត្រៃយ៍

ជូ ប៊ុនអេង